## វិធីបោះឆ្នោត

រដ្ឋកាលីហ្វ័រញ៉ា ហើយនិងទីក្រុងឡុងប៊ិច ផ្តល់វិធីពីរ ដើម្បីបោះឆ្នោត ។ លោកអ្នកអាចប្រើទីកន្លែងបោះឆ្នោតតាមរបៀបប្រពៃណី នៅថ្ងៃបោះឆ្នោត ឬមួយលោកអ្នកអាចបោះឆ្នោតតាមរយៈដំណើរការបោះឆ្នោតតាមប្រៃសណីយ៍ ។ វិធីទាំងពីរជាវិធីដ៏ត្រឹមត្រូវ ដើម្បីអនុវត្តសិទ្ធិបោះឆ្នោតរបស់លោកអ្នក ។

ការបោះឆ្នោតនៅឯកន្លែងបោះឆ្នោត មានតាំងពីកំណើតប្រទេសយើងម្ល៉េះ ។ អ្នកធ្វើការនៅកន្លែងបោះឆ្នោត ស្ថិតនៅក្បែរដើម្បីជួយលោកអ្នក ឱ្យយល់ពីវិធីដ៏ត្រឹមត្រូវ ក្នុងការគូសសន្លឹកឆ្នោត ជួយមនុស្សមានពិការភាពបែបណាក៏ដោយ ហើយនិងផ្តល់ជំនួយខាងភាសា បើសិនជាត្រូវការ ។

ការបោះឆ្នោតតាមប្រៃសណីយ៍ គឺត្រូវបានផ្តល់ជូនឱ្យអ្នកបោះឆ្នោតអស់ប៉ុន្មានឆ្នាំនេះហើយ ។ អ្នកបោះឆ្នោតដែលមានសិទ្ធិ អាចស្នើសុំសន្លឹកឆ្នោត ដើម្បីបោះឆ្នោតតាមប្រៃសណីយ៍ ប្រមាណមួយខែមុនការបោះឆ្នោត ហើយអាចបោះឆ្នោតដោយប្រើសន្លឹកឆ្នោតនោះ ពីផ្ទះខ្លួនឯង ដោយភាពលាក់ការណ៍ ។ ជំរើសដ៏ថ្មីមួយនៅក្នុងបណ្តាឆ្នាំកន្លងមកថ្មីៗនេះ គឺជាលទ្ធភាពឱ្យប្រកាសថា ខ្លួនឯងជាអ្នកបោះឆ្នោតអវត្តមានជាអចិន្ត្រៃយ៍ ។ រាល់ពេលមានការបោះឆ្នោត សន្លឹកឆ្នោតមួយនឹងត្រូវបានផ្ញើទៅទីលំនៅរបស់លោកអ្នក ដោយស្វ័យប្រវត្តិ ដោយលោកអ្នកមិនចាំបាច់ស្នើសុំវាទេ ។

ពត៌មានលំអិត អំពីរបៀបបោះឆ្នោត មានខាងក្រោមនេះ ក្នុងទ្រង់ទ្រាយជាសំណួរ និងចំឡើយ ។ សូមចងចាំ! វាមិនសំខាន់ថាលោកអ្នកបោះឆ្នោតតាមវិធីមួយណាទេ ឱ្យតែលោកអ្នកបោះឆ្នោត ។

### តើខ្ញុំត្រូវទៅណាដើម្បីបោះឆ្នោត/តើកន្លែងបោះឆ្នោតរបស់ខ្ញុំនៅឯណា?

កន្លែងបោះឆ្នោតរបស់លោកអ្នក ត្រូវបានបោះពុម្ពនៅលើក្របខាងក្រោយនៃកូនសៀវភៅគំរូសន្លឹកឆ្នោតរបស់លោកអ្នក ។ សូមឆែកឆេរអាស័យដ្ឋាននៃទីកន្លែងបោះឆ្នោត សំរាប់ការបោះឆ្នោតនីមួយៗ ពីព្រោះទីកន្លែងផ្លាស់ប្តូរជារឿយៗ ។ ម្យ៉ាងទៀត កន្លែងបោះឆ្នោតទាំងឡាយមានជំរាបជូនឯ www.LAVOTE.net ឬដោយហៅទៅ (562) 570-6101 ។

### តើអ្វីជាម៉ោងដំណើរការនៃកន្លែងបោះឆ្នោត?

កន្លែងបោះឆ្នោតបើកពីម៉ោង 7:00 ព្រឹក ទៅម៉ោង 8:00 យប់ ។

**តើហេតុអ្វីបានជាកន្លែងបោះឆ្នោតរបស់ខ្ញុំផ្លាស់ប្តូរ?**

នៅរដ្ឋកាលីហ្វ័រញ៉ា គ្មានកន្លែងបោះឆ្នោតអចិន្ត្រៃយ៍ទេ ។ ទីកន្លែងផ្លាស់ប្តូរពីការបោះឆ្នោតមួយ ទៅការបោះឆ្នោតមួយ បើសិនជាកន្លែងដែលបានប្រើពីមុន មិនទំនេរសំរាប់ការបោះឆ្នោតណាមួយ ។ ការផ្លាស់ប្តូរនៃព្រំដែនតំបន់បោះឆ្នោត អាចកើតឡើងជួនកាល នៅពេលដែលតំបន់បោះឆ្នោតផ្សេងគ្នាត្រូវបានរួមបញ្ចូលគ្នា ឬផ្លាស់ប្តូរព្រំដែន ជាពិសេស សំរាប់ការបោះឆ្នោតតាមទីក្រុងនិងស្រុក ដែលមិនមែនខាងរដ្ឋទាំងមូលទេ ។ អ្នកបោះឆ្នោតគួរតែមើលកូនសៀវភៅគំរូសន្លឹកឆ្នោតរបស់គេ ដើម្បីធ្វើឱ្យប្រាកដថា ទៅទីកន្លែងបោះឆ្នោតដ៏ត្រឹមត្រូវ ។

**តើត្រូវធ្វើដូចម្តេច បើកន្លែងបោះឆ្នោតរបស់ខ្ញុំមិនបានបើកទេ នៅពេលខ្ញុំមកដល់ក្នុងពេលព្រឹកនៃថ្ងៃបោះឆ្នោត?**

ឆែកឆេរអាស័យដ្ឋាននៅក្របខាងក្រោយនៃកូនសៀវភៅគំរូសន្លឹកឆ្នោត ដើម្បីបញ្ជាក់ថា លោកអ្នកបានទៅកន្លែងដ៏ត្រឹមត្រូវ ។ ជារឿយៗ កន្លែងបោះឆ្នោតផ្លាស់ប្តូរ ក្នុងចន្លោះពេលរវាងការបោះឆ្នោតផ្សេងៗ ។ បើលោកអ្នកបានទៅដល់កន្លែងត្រឹមត្រូវ សូមហៅទៅនាយកដ្ឋានស្មៀនក្រុង លេខ (562) 570-6101 ដើម្បីរាយការណ៍ថា កន្លែងបោះឆ្នោតមិនទាន់បើក ។

**តើខ្ញុំអាចយកគំរូសន្លឹកឆ្នោត ឬជំរើសបោះឆ្នោតដែលខ្ញុំបានសរសេររួច ចូលទៅក្នុងបន្ទប់បោះឆ្នោតជាមួយខ្ញុំបាន ឬទេ?**

បាន ។ យើងឱ្យយោបល់ថា គួរតែគូសជំរើសបោះឆ្នោតរបស់លោកអ្នកនៅលើគំរូសន្លឹកឆ្នោតរបស់លោកអ្នក ហើយយកវាទៅកន្លែងបោះឆ្នោតរបស់លោកអ្នកនៅថ្ងៃបោះឆ្នោត ដើម្បីមើលតាមវា ។ ការនេះនឹងជួយលោកអ្នកឱ្យបោះឆ្នោតលឿន ។ សូមចងចាំឱ្យយកគំរូសន្លឹកឆ្នោតរបស់អ្នកចេញពីបន្ទប់បោះឆ្នោត នៅពេលលោកអ្នកបោះឆ្នោតរួច ។

**បើមិនដឹងធ្វើអ្វីនៅពេលទៅដល់កន្លែងបោះឆ្នោត តើមានអ្នកណាជួយខ្ញុំ ឬទេ?**

មាន ។ សូមអ្នកធ្វើការក្នុងកន្លែងបោះឆ្នោត ឱ្យជួយលោកអ្នកក្នុងដំណើរការបោះឆ្នោត ។ អ្នកធ្វើការនៅកន្លែងបោះឆ្នោត គ្មានសិទ្ធិដើម្បីជួយលោកអ្នកធ្វើការសំរេចចិត្តរបស់អ្នក ស្តីអំពីជំរើសបោះឆ្នោតនោះទេ ។

**តើខ្ញុំអាចបោះឆ្នោតជ្រើសរើសអ្នកណាម្នាក់ ដែលគ្មានឈ្មោះនៅលើសន្លឹកឆ្នោត បានឬទេ?**

បាន បើសិនជាអ្នកនោះត្រូវបានបញ្ជាក់ជាបេក្ខជនដែលអាចសរសេរចុះឈ្មោះទៅលើសន្លឹកឆ្នោតបាន ។ មានតែការបោះឆ្នោតជ្រើសរើសបេក្ខជនណា ដែលត្រូវបានបញ្ជាក់សំរាប់ការសរសេរចុះឈ្មោះលើសន្លឹកឆ្នោតតែប៉ុណ្ណោះ ដែលនឹងត្រូវបានរាប់ ។ សួរអ្នកធ្វើការក្នុងកន្លែងបោះឆ្នោត ឬទូរស័ព្ទទៅនាយកដ្ឋានស្មៀនក្រុង ដើម្បីសូមបញ្ជីរាយឈ្មោះបេក្ខជនទាំងនោះ ។  អ្នកធ្វើការក្នុងកន្លែងបោះឆ្នោត ឬបុគ្គលិកនៃនាយកដ្ឋានស្មៀនក្រុង អាចជួយលោកអ្នក ជាមួយទំរង់ការនៃការបោះឆ្នោតដោយសរសេរចុះឈ្មោះទៅលើសន្លឹកឆ្នោត ។

**តើអ្នកណាខ្លះ អាចបោះឆ្នោតតាមប្រៃសណីយ៍?**

អ្នកណាក៏ដោយ ដែលបានចុះឈ្មោះជាអ្នកបោះឆ្នោត អាចដាក់ពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍បាន ។

**តើខ្ញុំអាចបោះឆ្នោតតាមប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន យ៉ាងដូចម្ដេច?**

ការបោះឆ្នោតតាមប្រៃសណីយ៍ គឺដូចគ្នានឹងការបោះឆ្នោតតាមរយៈសន្លឹកឆ្នោតអវត្តមាន ។ ជំនួសការទៅបោះឆ្នោតនៅកន្លែងបោះឆ្នោត នៅថ្ងៃបោះឆ្នោត លោកអ្នកអាចស្នើសុំសន្លឹកឆ្នោតមួយសំរាប់ការបោះឆ្នោតតាមប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន ។ ការដាក់ពាក្យសុំនោះ គឺងាយស្រួល ។ គ្រាន់តែជ្រើសរើសពីជំរើសមួយខាងក្រោមនេះ :

· តាមប្រៃសណីយ៍ : 1) បំពេញពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន ដែលនៅក្របខាងក្រោយនៃកូនសៀវភៅគំរូសន្លឹកឆ្នោត (ដែលបានផ្ញើទៅលោកអ្នក មុនការបោះឆ្នោតនីមួយៗ) ហើយផ្ញើវាទៅនាយកដ្ឋានស្មៀនក្រុង ។

· តាមប្រៃសណីយ៍ : 2) ផ្ញើសំបុត្រមានហត្ថលេខាមួយ ស្នើសុំសន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន ទៅ Long Beach City Clerk Department, 333 W. Ocean Blvd., Long Beach, CA 90802 ។

· តាមទូរសារ : លោកអ្នកក៏អាចបញ្ជូនពាក្យសុំ ឬសំបុត្រមានហត្ថលេខា តាមទូរសារទៅនាយកដ្ឋានស្មៀនក្រុង នៅលេខ (562) 570-6789 ។ បើលោកអ្នកដាក់ពាក្យតាមរយៈសំបុត្រ ឬទូរសារ សំណើរបស់លោកអ្នកត្រូវតែមានឈ្មោះ អាស័យដ្ឋានផ្ទះ/ទីលំនៅ អាស័យដ្ឋានផ្ញើសំបុត្រ ដែលជាកន្លែងលោកអ្នកចង់ទទួលសន្លឹកឆ្នោតអវត្តមាន ហើយនិងឈ្មោះ និងថ្ងៃ/ខែ/ឆ្នាំ នៃការបោះឆ្នោតដែលលោកអ្នកកំពុងដាក់ពាក្យសុំសំរាប់នោះ ។ កុំភ្លេចចុះហត្ថលេខា ហើយនិងថ្ងៃ/ខែ/ឆ្នាំ នៅលើសំណើរបស់លោកអ្នក!

· តាមបណ្ដាញអ៊ិនធឺណិត : ដោនឡូដ ហើយបំពេញនូវពាក្យសុំសន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន ហើយបញ្ជូនតាមទូរសារមកនាយកដ្ឋានស្មៀនក្រុង នៅលេខ (562) 570-6789 ។ ពត៌មានថែមទៀត អាចរកបានដោយទូរស័ព្ទទៅផ្នែកអ្នកបោះឆ្នោតអវត្តមាននៃនាយកដ្ឋានស្មៀនក្រុង នៅលេខ (562) 570-6101 ។

**តើខ្ញុំអាចដាក់ពាក្យសុំសន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន នៅពេលណា?**

· 29 ថ្ងៃមុនការបោះឆ្នោត គឺជាថ្ងៃដំបូងដើម្បីដាក់ពាក្យសុំសន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន ។ លោកអ្នកអាចដាក់ពាក្យមុន 29 មុនបាន ក៏ប៉ុន្តែសន្លឹកឆ្នោតត្រូវបានផ្ញើទៅអ្នកសុំ ចាប់ផ្ដើមថ្ងៃដំបូងដែលច្បាប់អនុញ្ញាតឱ្យផ្ញើ គឺ 29 ថ្ងៃមុនការបោះឆ្នោត ។

· ថ្ងៃចុងក្រោយ ដើម្បីដាក់ពាក្យសុំសន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន គឺ 7 ថ្ងៃមុនថ្ងៃបោះឆ្នោត ។

· បើលោកអ្នកធ្លាក់ខ្លួនឈឺ ពិការ ឬបានដំណឹងថាលោកអ្នកនឹងត្រូវទៅឆ្ងាយពីកន្លែងបោះឆ្នោតរបស់អ្នក នៅក្នុងរយៈពេល 6 ថ្ងៃមុនការបោះឆ្នោត លោកអ្នកអាចបោះឆ្នោតដោយសន្លឹកឆ្នោតអវត្តមានអាសន្ន ។ លោកអ្នកអាចបោះឆ្នោតដោយផ្ទាល់ខ្លួននៅឯនាយកដ្ឋានស្មៀនក្រុង ឬលោកអ្នកអាចផ្ញើសំបុត្រលាយល័ក្ខណ៍អក្សរ/មានហត្ថលេខា ស្នើសុំសន្លឹកឆ្នោតអវត្តមាន ដែលសំបុត្រនោះអនុញ្ញាតឱ្យមនុស្សម្នាក់ទៀតយកសន្លឹកឆ្នោតមួយទៅឱ្យលោកអ្នក រួចហើយយកវាមកការិយាល័យបោះឆ្នោត ឬកន្លែងបោះឆ្នោតណាមួយ បន្ទាប់ពីលោកអ្នកបោះឆ្នោតហើយ ។

**តើថ្ងៃណាជាថ្ងៃចុងក្រោយ ដើម្បីផ្ញើទៅវិញ នូវសន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន ដែលបំពេញរួច?**

ការិយាល័យបោះឆ្នោតត្រូវតែទទួលសន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន មិនហួសពីម៉ោងបិទកន្លែងបោះឆ្នោត (គឺម៉ោង 8 យប់) នៅថ្ងៃបោះឆ្នោត ។ យើងមិនគិតត្រាប្រៃសណីយ៍ទេ!

**តើធ្វើដូចម្តេចដើម្បីដាក់សន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមានរបស់ខ្ញុំ នៅថ្ងៃបោះឆ្នោត?**

លោកអ្នកអាចយកវាដោយផ្ទាល់ខ្លួនទៅកន្លែងបោះឆ្នោតមួយណាក៏បាន នៅក្នុងទីក្រុង ឱ្យទាន់ម៉ោង 8:00 យប់ នៅថ្ងៃបោះឆ្នោត ។ បើលោកអ្នកមិនអាចយកសន្លឹកឆ្នោតទៅដោយខ្លួនឯងបានទេ ដោយសារមានជំងឺ ឬពិការភាព នោះលោកអ្នកអាចអនុញ្ញាត ជាលាយល័ក្ខណ៍អក្សរ ឱ្យប្តី/ប្រពន្ធ កូន ឪពុក/ម្តាយ ជីដូន/ជីតា ចៅ ឬបងប្អូន យកសន្លឹកឆ្នោតមកការិយាល័យបោះឆ្នោត ឬទៅកន្លែងបោះឆ្នោតមួយណាក៏បាននៅក្នុងទីក្រុង ឱ្យទាន់ម៉ោង 8:00 យប់ នៅថ្ងៃបោះឆ្នោត ។

**តើមានកាលៈទេសៈអ្វី ដែលអ្នកបោះឆ្នោតម្នាក់អាចត្រូវបានគេតំរូវឱ្យបោះឆ្នោតតាមប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមានទេ?**

មាន ។ បើតំបន់បោះឆ្នោតណាមួយ មានអ្នកចុះឈ្មោះបោះឆ្នោតតែ 250 នាក់ ឬតិចជាង នៅថ្ងៃទី 88 មុនការបោះឆ្នោត តំបន់នោះអាចត្រូវភ្នាក់ងារបោះឆ្នោតប្រកាសថា ជា "តំបន់បោះឆ្នោតតាមប្រៃសណីយ៍" ដោយសារការខ្វះខាតកន្លែងបោះឆោត និងអ្នកធ្វើការនៅកន្លែងបោះឆ្នោត នៅក្នុងតំបន់បោះឆ្នោតដ៏តូច ។ គ្រប់អ្នកបោះឆ្នោតម្នាក់ៗ នៅក្នុងតំបន់បោះឆ្នោតបែបនេះ នឹងទទួលសន្លឹកឆ្នោតសំរាប់បោះឆ្នោតតាមប្រៃសណីយ៍ សំរាប់ការបោះឆ្នោតលើកនោះ ដោយស្វ័យប្រវត្តិ ។

**តើខ្ញុំចាំបាច់ដាក់ពាក្យសុំសន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន សំរាប់ការបោះឆ្នោតនីមួយៗទេ?**

អត់ទេ ។ លោកអ្នកអាចដាក់ពាក្យសុំធ្វើជា "អ្នកបោះឆ្នោតអវត្តមានអចិន្ត្រៃយ៍" ។ នៅពេលដែលឈ្មោះលោកអ្នកត្រូវបានចុះជាអ្នកបោះឆ្នោតអវត្តមានអចិន្ត្រៃយ៍ លោកអ្នកមិនបាច់ដាក់ពាក្យទៀតទេ សំរាប់ការបោះឆ្នោតនាអនាគត ។ សន្លឹកឆ្នោតមួយនឹងត្រូវបានផ្ញើទៅលោកអ្នកដោយស្វ័យប្រវត្តិ សំរាប់ការបោះឆ្នោតនីមួយៗ ។ នៅពេលដែលអ្នកបោះឆ្នោតណាម្នាក់ ត្រូវបានអនុម័តជាអ្នកបោះឆ្នោតអវត្តមានអចិន្ត្រៃយ៍ហើយ គាត់នឹងរក្សាទុកឋានៈនេះ ដរាបណាគាត់បោះឆ្នោតក្នុងការបោះឆ្នោតប្រចាំរដ្ឋរាល់ដង ។ ដើម្បីរកពត៌មានថែមទៀតអំពីការក្លាយជាអ្នកបោះឆ្នោតអវត្តមានអចិន្ត្រៃយ៍ សូមមើលកូនសៀវភៅគំរូសន្លឹកឆ្នោត ឬទូរស័ព្ទទៅអ្នកកាន់បញ្ជី-កត់បញ្ជីស្រុកឡូសអាន់ចេឡែស/ផ្នែកបោះឆ្នោតអវត្តមាននៃស្មៀនស្រុក នៅលេខ (562) 466-1323 ។

**បើខ្ញុំស្នើសុំសន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន តើខ្ញុំអាចប្តូរគំនិត ហើយនៅតែបោះឆ្នោតនៅឯកន្លែងបោះឆ្នោតរបស់ខ្ញុំ បានទេ?**

បាន ប៉ុន្តែសូមយកសន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមានរបស់អ្នកទៅកន្លែងបោះឆ្នោត ហើយប្រគល់វាទៅឱ្យអ្នកធ្វើការក្នុងកន្លែងបោះឆ្នោត មុនលោកអ្នកបោះឆ្នោតដោយសន្លឹកឆ្នោតធម្មតា ។ បើលោកអ្នកមិនមានសន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន ដើម្បីប្រគល់ឱ្យគេទេ លោកអ្នកនឹងត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតដោយ "បណ្តោះអាសន្ន" នៅឯទីកន្លែងបោះឆ្នោត ។ សន្លឹកឆ្នោតបណ្តោះអាសន្នរបស់លោកអ្នកនឹងត្រូវបានរាប់ ក្រោយពីភ្នាក់ងារបោះឆ្នោតបញ្ជាក់ថា លោកអ្នកមិនបានបោះឆ្នោតពីមុន ដោយប្រើសន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន សំរាប់ការបោះលើកនោះទេ ។

**ខ្ញុំបានទទួលពាក្យសុំសន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន ពីយុទ្ធនាការនយោបាយមួយ ។ តើការប្រើពាក្យសុំនោះ គឺស្របច្បាប់ឬទេ?**

ស្របច្បាប់ ។ បុគ្គល អង្គការ និងក្រុមផ្សេងៗ អាចចែកពាក្យសុំសន្លឹកឆ្នោតប្រៃសណីយ៍/សន្លឹកឆ្នោតអវត្តមាន ក៏ប៉ុន្តែក្រដាសនោះត្រូវតែមានទ្រង់ទ្រាយតាមខ្នាត ដែលបានបញ្ជាក់នៅក្នុងក្រមបោះឆ្នោតនៃរដ្ឋកាលីហ្វ័រញ៉ា ។